ប្រ.ក/លេខ០៨.០៨៩/០៦ គ.ជ.ប.អគ្គ.ពស    ភ្នំពេញ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៦

# ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ បានចេញប្រើជាផ្លូវការ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានអនុម័តប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ ដើម្បីផ្សព្វផ្សាយឱ្យសាធារណជនបានដឹង អំពីដំណាក់ការនីមួយៗនៃដំណើរការបោះឆ្នោត ។

ប្រតិទិននេះបានបញ្ជាក់ពីកាលបរិច្ឆេទច្បាស់លាស់ អំពីដំណាក់ការនីមួយៗនៃដំណើរការបោះឆ្នោត ដែលបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយ ក្នុងការរៀបចំត្រៀមឯកសារដើម្បីចូលរួមប្រកួតប្រជែង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ខាងមុខនេះ ។

យោងតាមប្រតិទិននេះ មានចំណុចសំខាន់ៗដូចជា :

-ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៦ ។

-ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ៣ ខែមករា ឆ្នាំ ២០០៧ ។

-ការឃោសនាបោះឆ្នោត នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៧ ។

-ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត នៅថ្ងៃទី ១ ខែមេសា ឆ្នាំ ២០០៧ ។

អ្នកសារព័ត៌មាន ឬស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត អាចទំនាក់ទំនងរកប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧ នេះបាននៅការិយាល័យព័ត៌មានសាធារណៈនៃ គ.ជ.ប ។ ម្យ៉ាងទៀតប្រតិទិនសម្រាប់ការបោះឆ្នោតនេះក៏ត្រូវបានផ្សព្វផ្សាយតាមរយៈ Website គ.ជ.ប E-mail និងតាមទូរសារទៅគ្រប់ស្ថាប័នពាក់ព័ន្ធផងដែរ ។

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦

# ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧

| ការកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ( *បញ្ជីបោះឆ្នោតឆ្នាំ២០០៥* ) | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ |
| ការចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ១ ខែតុលា ឆ្នាំ២០០៦ |
| ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីដំបូង តាមករណីគ្មានបណ្ដឹង ឬដោះស្រាយបណ្ដឹងរួចរាល់ | ថ្ងៃទី២៤ ខែតុលា ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ |
| ការផ្ដល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតនៅ គឃ/សប | ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ |
| ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ រយៈពេល៣ថ្ងៃ ដោយ គឃ/សប | ថ្ងៃទី១-៣ ខែមករា ឆ្នាំ២០០៧ |
| ការសម្រេចរបស់ គឃ/សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបេក្ខជនដំបូងនៅ គឃ/សប | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ នៅ គឃ/សប | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី១៦-៣០ ខែមីនា ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៧ |
| ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ |
| ការត្រួតពិនិត្យ បូកសរុប និងបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៅ គឃ/សប រយៈពេល៣ថ្ងៃ | ថ្ងៃទី២-៤ ខែមេសា ឆ្នាំ២០០៧ |
| ការប្ដឹងជំទាស់ពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅតាមឃុំ សង្កាត់ទៅ គខ/គប រយៈពេលយ៉ាងយូរ៣ថ្ងៃ បន្ទាប់ពីបិទផ្សាយនៅតាមឃុំ សង្កាត់នោះ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៧ |
| ការសម្រេចលើបណ្ដឹងជំទាស់ដោយ គខ/គប រយៈពេល៥ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្ដឹង | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ |
| ការប្ដឹងតវ៉ាលើសេចក្ដីសម្រេចរបស់ គខ/គប ទៅ គ.ជ.ប រយៈពេល៤ថ្ងៃ បន្ទាប់ពីទទួលទំរង់បែបបទបដិសេធ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៧ |
| ការសម្រេចលើបណ្ដឹងតវ៉ាដោយ គ.ជ.ប រយៈពេល៤ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ |
| ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧ |
| ការបោះឆ្នោតសាជាថ្មី | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧ |